ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ..៩៦៤........សុខ.ម

ថ្ងៃព្រហស្បតិ៍ ៦រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០២០..

# សេចក្តីជូនដំណឹង

## ស្តីពី

## ការគិតថ្លៃសេវាធ្វើតេស្តរកមេរោគកូវីដ១៩ ការធ្វើចត្តាឡីស័ក និងការពិនិត្យព្យាបាលជំងឺកូវីដ១៩ នៅមន្ទីរពេទ្យរដ្ឋ សម្រាប់ជនបរទេសចូលមកប្រទេសកម្ពុជា

អនុលោមតាមអនុក្រឹត្យលេខ ១២៥ អនក្រ.បក ចុះថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់និងឆ្លើយតបការឆ្លងរាលដាលអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល ស្មារតីនៃកិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩ កាលពីថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០២០ និងលិខិតលេខ ៨៨៥៨ សហវ ចុះថ្ងៃទី ៨ ខែមិថុនា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកំណត់ថ្លៃសេវាពីអ្នកដំណើរជាជនបរទេសចូលមកប្រទេសកម្ពុជា ក្នុងអំឡុងពេលអនុវត្តវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ និងឆ្លើយតបការឆ្លងរាលដាលនៃជំងឺកូវីដ១៩ ក្រសួងសុខាភិបាល មានកិត្តិយស សូមជម្រាបជូនដំណឹងដល់គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងជនបរទេសដែលចូលមកប្រទេសកម្ពុជា ជ្រាបអំពីការគិតថ្លៃសេវាពីជនបរទេសដែលចូលមកប្រទេសកម្ពុជា សម្រាប់ការធ្វើតេស្តរកមេរោគកូវីដ១៩ ការធ្វើចត្តាឡីស័ក និងការពិនិត្យ ព្យាបាលអ្នកជំងឺកូវីដ១៩ នៅមន្ទីរពេទ្យរដ្ឋ ដូចខាងក្រោម៖

១.ការបង់ថ្លៃសម្រាប់អ្នកដំណើរជនបរទេសដែលចូលមកប្រទេសកម្ពុជា ក្នុងអំឡុងពេលរង់ចាំយកសំណាកវិភាគ រហូតដល់ការចេញលទ្ធផលតេស្តកូវីដ១៩

| ល.រ | អធិប្បាយមុខចំណាយ | តម្លៃឯកតា |
|---|---|---|
| ១ | ថ្លៃដឹកជញ្ជូនពីព្រលានយន្តហោះ ទៅមណ្ឌលសំចត រង់ចាំធ្វើតេស្ត និងទទួលលទ្ធផលតេស្ត | ៥ដុល្លារ/១នាក់/១ជើង |
| ២ | តម្លៃយកសំណាក និងដឹកជញ្ជូនសំណាកទៅមន្ទីរពិសោធន៍ដើម្បីធ្វើតេស្ត និងការចេញលទ្ធផល | ១០០ ដុល្លារ/១ដង/១នាក់ |
| ៣ | តម្លៃស្នាក់នៅក្នុងសណ្ឋាគារ ឬ មណ្ឌលសំចត ដែលកំណត់ដោយគណៈកម្មការអន្តរក្រសួង | ៣០ដុល្លារ/១ថ្ងៃ/១នាក់ |
| ៤ | ថ្លៃអាហារបីពេល | ៣០ដុល្លារ/១ថ្ងៃ/១នាក់ |

២.ការបង់ថ្លៃសម្រាប់អ្នកដំណើរអវិជ្ជមាន ដែលរួមដំណើរជាមួយអ្នកដំណើរវិជ្ជមាន ដែលត្រូវធ្វើចត្តាឡីស័កនៅសណ្ឋាគារ ឬ តាមមណ្ឌលចត្តាឡីស័ក រយៈពេល១៤ថ្ងៃ

| ល.រ | អធិប្បាយមុខចំណាយ | តម្លៃឯកតា |
|---|---|---|
| ១ | ថ្លៃដឹកជញ្ជូន | ៥ដុល្លារ/១នាក់/១ជើង |
| ២ | តម្លៃស្នាក់នៅក្នុងសណ្ឋាគារ ឬ មណ្ឌលចត្តាឡីស័ក | ៣០ដុល្លារ/១ថ្ងៃ/១នាក់ |



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

| | | |
|---|---|---|
| ៣ | តម្លៃយកសំណាក និងដឹកជញ្ជូនសំណាកទៅមន្ទីរពិសោធន៍ដើម្បីធ្វើតេស្ត និងការចេញលទ្ធផល | ១០០ ដុល្លារ/១ដង/១នាក់ |
| ៤ | ថ្លៃអាហារបីពេល | ៣០ដុល្លារ/១ថ្ងៃ/១នាក់ |
| ៥ | សេវាបោកគក់ និងអនាម័យ | ១៥ដុល្លារ/១ថ្ងៃ/១នាក់ |
| ៦ | សេវាគ្រូពេទ្យប្រចាំការសម្រាប់រយៈពេលចត្តាឡីស័ក ក្នុងមួយមណ្ឌល (គិតជាកញ្ចប់) | ៦ដុល្លារ/១ថ្ងៃ/១នាក់ |
| ៧ | សេវាសន្តិសុខ (គិតជាកញ្ចប់) | ៣ដុល្លារ/១ថ្ងៃ/១នាក់ |

៣.ការបង់ថ្លៃក្នុងការពិនិត្យនិងព្យាបាលអ្នកជំងឺកូវីដ១៩ ថ្លៃមាននៅមន្ទីរពេទ្យរដ្ឋ

| ល.រ | អធិប្បាយមុខចំណាយ | តម្លៃឯកតា |
|---|---|---|
| ១ | ថ្លៃដឹកជញ្ជូន | ៥ដុល្លារ/១នាក់/១ជើង |
| ២ | ការធ្វើតេស្ត (អប្បរមាចំនួន ៤ដង) | ១០០ដុល្លារ/១នាក់/១ដង |
| ៣ | ថ្លៃបន្ទប់ក្នុងមន្ទីរពេទ្យ | ៣០ដុល្លារ/១ថ្ងៃ/១នាក់ |
| ៤ | ថ្លៃព្យាបាល រួមទាំងថ្លៃថ្នាំ | អតិបរមា ១៥០ដុល្លារ/១ថ្ងៃ/១នាក់ |
| ៥ | ថ្លៃអាហារបីពេល | ៣០ដុល្លារ/១ថ្ងៃ/១នាក់ |
| ៦ | សេវាបោកគក់ | ១៥ដុល្លារ/១ថ្ងៃ/១នាក់ |
| ៧ | សេវាសង្គ្រោះបន្ទាន់ | តាមតារាងតម្លៃសេវាដែលមានស្រាប់របស់មន្ទីរពេទ្យ |
| ៨ | ករណីពិនិត្យ ព្យាបាលជំងឺប្រចាំកាយ ផ្សេងៗ | តាមតារាងតម្លៃសេវាដែលមានស្រាប់របស់មន្ទីរពេទ្យ |
| ៩ | បូជាសព | ១ ៥០០ដុល្លារ/១នាក់ |

៤.ការចេញលិខិតបញ្ជាក់សុខភាពពាក់ព័ន្ធជំងឺកូវីដ១៩

| ល.រ | អធិប្បាយមុខចំណាយ | តម្លៃឯកតា |
|---|---|---|
| ១ | ការធ្វើតេស្ត | ១០០ដុល្លារ/១នាក់/១ដង |
| ២ | ចេញវិញ្ញាបនបត្របញ្ជាក់សុខភាព | ៣០ដុល្លារ/១នាក់/១ដង |

អ្នកដំណើរជាជនបរទេស ដែលបានមកដល់ព្រះរាជាណាចក្រកម្ពុជា ត្រូវមានឯកសារធានារ៉ាប់រងសុខភាពក្នុងទឹកប្រាក់យ៉ាងតិច ៥០.០០០ (ហាសិបពាន់) ដុល្លារអាមេរិក និងមានប្រាក់តំកល់ (ជាសាច់ប្រាក់ ឬប័ណ្ណឥណពន្ធ) ហើយត្រូវបង្កក់នៅធនាគារពាណិជ្ជដែលកំណត់នៅទីតាំងព្រំដែននីមួយៗ ដែលមានចំនួនយ៉ាងតិច ៣.០០០ (បីពាន់) ដុល្លារអាមេរិក ហើយថវិកានេះត្រូវរក្សាទុកដើម្បីធ្វើការទូទាត់ចំណាយផ្សេងៗ ក្នុងពេលអនុវត្តវិធានការសុខាភិបាល។ សេចក្តីជូនដំណឹងនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជា**
**ប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩**

**ម៉ម ប៊ុនហេង**